# កិច្ចប្រជុំលើកទី ១៨ របស់ គ.ជ.អ.ប.

## របាយការណ៍សង្ខេប

## វឌ្ឍនភាព និងបញ្ហាប្រឈមរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្នុងក្របខណ្ឌនៃការអនុវត្តមុខងារ និងរចនាសម្ព័ន្ធថ្មី

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២០

# មាតិកា

I. អំពីវឌ្ឍនភាព

II. អំពីបញ្ហាប្រឈម

III. អំពីផែនការបន្ទាប់

# I. អំពីវឌ្ឍនភាព

- ការរៀបចំពិធីផ្សព្វផ្សាយអនុក្រឹត្យស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង ស្រុក ខណ្ឌ នាថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ២០១៩។ កិច្ចការជាអាទិភាពដែលសម្រេចបាន រួមមាន៖

១. <u>ការផ្ទេរបុគ្គលិកទៅឱ្យក្រុង ស្រុក ខណ្ឌចំនួន២០៣</u>

- ✓ នាខែមករា ឆ្នាំ២០២០ គ.ជ.អ.ប បានផ្ទេរបុគ្គលិកចំនួន **១៩.៥៩៣ នាក់** ទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្នុងនោះ ៖
  - ○ បុគ្គលិកដែលបានផ្ទេរពីក្រសួងមហាផ្ទៃចំនួន **៥.៣៥៥ នាក់**
  - ○ បុគ្គលិកក្រសួងជំនាញមានចំនួន **១៤.២៣៨ នាក់** (រួមទាំងគ្រូបង្រៀនចំនួន **៦.៥១៩ នាក់**)
- ✓ បច្ចុប្បន្ន ធនធានមនុស្សសរុបមានចំនួន **២៤.៧៧១ នាក់** ក្នុងនោះ៖
  - ○ ក្រុមប្រឹក្សាចំនួន **៣.៥៥៥ នាក់**
  - ○ គណៈអភិបាលចំនួន **១.០១៤ នាក់**
  - ○ នាយក នាយករងរដ្ឋបាលចំនួន **៦០៩ នាក់**
  - ○ បុគ្គលិកការិយាល័យ និងអង្គភាពនានាចំនួន **១៩.៥៩៣ នាក់**។

# I. អំពីវឌ្ឍនភាព (ត)

## ២. ការប្រកាសដាក់ឱ្យដំណើរការ

- ✓ ក្នុងនាមរាជរដ្ឋាភិបាល រដ្ឋបាលរាជធានី ខេត្ត បានរៀបចំពិធីប្រកាស និងដាក់ឱ្យអនុវត្តនូវរចនាសម្ព័ន្ធថ្មីរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌទាំង២០៣ រួចរាល់តាំងពីខែកុម្ភៈ ឆ្នាំ២០២០។

## ៣. ការបណ្តុះបណ្តាល

- ✓ សាលាជាតិរដ្ឋបាលមូលដ្ឋានបានរៀបចំវគ្គបណ្តុះបណ្តាលតម្រង់ទិសអំពីមុខងារ រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងថ្មីរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌជូនដល់មន្ត្រីថ្នាក់ដឹកនាំរដ្ឋបាលក្រុង ស្រុក ខណ្ឌបានចំនួនប្រមាណ៨០%ដែលមានអ្នកចូលរួមសរុបចំនួន **៤.៨០០នាក់។** វគ្គបណ្តុះបណ្តាលបានផ្អាកមួយរយៈដោយសារការឆ្លងរាលដាលនៃជំងឺកូវីដ-១៩
- ✓ បច្ចុប្បន្ន កំពុងបន្តការបណ្តុះបណ្តាលដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌដែលនៅសេសសល់ ២០%ទៀត ដោយត្រូវអនុវត្តតាមវិធានការការពារទប់ស្កាត់ការរីករាលនៃជំងឺកូវីដ-១៩

# I. អំពីវឌ្ឍនភាព (ត)

## ៣. ការបណ្តុះបណ្តាល (ត)

- ✓ ចំពោះការបណ្តុះបណ្តាលអំពីជំនាញបច្ចេកទេស រួមមាន ភាពជាអ្នកដឹកនាំ ការគ្រប់គ្រងរដ្ឋបាល ការគ្រប់គ្រងហិរញ្ញវត្ថុនិងទ្រព្យសម្បត្តិ ការគ្រប់គ្រងបុគ្គលិក ការងារផែនការ ការងារអប់រំ និងអំពីគោលការណ៍ នីតិវិធី និងស្តង់ដាផ្តល់សេវាតាមវិស័យនានា ក្រុមការងារបណ្តុះបណ្តាលអន្តរក្រសួងបាន និងកំពុងរៀបចំ**សេចក្តីណែនាំបច្ចេកទេស** និង**ឯកសារចាំបាច់នានា**សម្រាប់ការបណ្តុះបណ្តាលនៅក្នុងឆមាសទី២នៃឆ្នាំ២០២០នេះ។

# I. អំពីវឌ្ឍនភាព (ត)

## ៤. ការរៀបចំលិខិតបទដ្ឋាន និងឯកសារពាក់ព័ន្ធ

- ✓ ក្រសួងមហាផ្ទៃបានរៀបចំ និងដាក់ចេញនូវសេចក្ដីណែនាំស្ដីពីការធានានិរន្តរភាពការងាររដ្ឋបាល និងការផ្ដល់សេវាក្នុងដំណើរការរៀបចំរចនាសម្ព័ន្ធថ្មីនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងបានផ្សព្វផ្សាយឱ្យអនុវត្តដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌទូទាំងប្រទេស
- ✓ ក្រសួងចំនួន០៧ រួមមាន ក្រសួងបរិស្ថាន ក្រសួងសាធារណការ ក្រសួងកិច្ចការនារី ក្រសួងកសិកម្ម ក្រសួងសង្គមកិច្ច ក្រសួងឧស្សាហកម្ម និងក្រសួងរ៉ែ និងថាមពលបាន និងកំពុងរៀបចំសេចក្ដីណែនាំបច្ចេកទេសសម្រាប់អនុវត្តមុខងារដែលបានផ្ទេរ
- ✓ រដ្ឋបាលរាជធានីភ្នំពេញបានដាក់ចេញនូវដីកាប្រតិភូកម្មមុខងារពីរដ្ឋបាលរាជធានីទៅឱ្យរដ្ឋបាលខណ្ឌទាំង ១៤ តាមស្មារតីនៃអនុក្រឹត្យស្ដីពីមុខងារ និងរចនាសម្ព័ន្ធរបស់រដ្ឋបាលខណ្ឌ
- ✓ លេខាធិការដ្ឋាន បានរៀបចំសេចក្ដីព្រាងបឋមអំពីការពិពណ៌នាមុខតំណែងវិជ្ជាជីវៈសម្រាប់ការិយាល័យ និងអង្គភាពនីមួយៗនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលរួមមានមុខតំណែងវិជ្ជាជីវៈចំនួន **៥៣**។

# I. អំពីវឌ្ឍនភាព (ត)

## ៥. ការផ្ទេរធនធានថវិកា

លេខាធិការដ្ឋាន គ.ជ.អ.ប. សហការជាមួយក្រុមការងារក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងពាក់ព័ន្ធបានរៀបចំលិខិតបទដ្ឋានគតិយុត្តសម្រាប់ផ្ទេរថវិកាទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលក្នុងនោះរួមមាន៖

- ✓ ប្រកាសអន្តរក្រសួងរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ និងក្រសួងអប់រំ យុវជន និងកីឡា ដើម្បីផ្ទេរថវិកាទៅឱ្យរដ្ឋបាលក្រុង ស្រុកទាំង១៤ក្នុងខេត្តបាត់ដំបងសម្រាប់អនុវត្តមុខងារការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ។ ប្រកាសនេះបានចុះហត្ថលេខាដោយរដ្ឋមន្ត្រីក្រសួងទាំង៣នាពេលថ្មីៗនេះ។
- ✓ លេខាធិការដ្ឋាន បាន និងកំពុងសហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក្នុងការរៀបចំលិខិតបទដ្ឋានដើម្បីផ្ទេរថវិកាបន្ថែមទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌសម្រាប់អនុវត្តមុខងារដែលបានផ្ទេរក្នុងវិស័យទាំង២០។ ទោះបីយ៉ាងនេះក៏ដោយ ក៏មានបញ្ហាប្រឈមមួយចំនួនដែលលេខាធិការដ្ឋាននឹងរាយការណ៍លម្អិតនៅផ្នែកនៃបញ្ហាប្រឈម។

# I. អំពីវឌ្ឍនភាព (ត)

## ៦. ការផ្ទេរទ្រព្យសម្បត្តិ

- ✓ លេខាធិការដ្ឋាន គ.ជ.អ.ប. សហការជាមួយក្រុមការងារក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងការសម្របសម្រួលជាមួយក្រសួងពាក់ព័ន្ធដើម្បីស្រង់ទិន្នន័យទ្រព្យសម្បត្តិដែលត្រូវផ្ទេរទៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ
- ✓ បច្ចុប្បន្ន លេខាធិការដ្ឋាន បានទទួលបញ្ជីស្រង់ទិន្នន័យទ្រព្យសម្បត្តិពី**ក្រសួងចំនួន១២** រួមមាន ក្រសួងអប់រំ ក្រសួងបរិស្ថាន ក្រសួងរ៉ែ និងថាមពល ក្រសួងឧស្សាហកម្ម ក្រសួងកិច្ចការនារី ក្រសួងការងារ ក្រសួងសាធារណការ ក្រសួងវប្បធម៌ ក្រសួងពាណិជ្ជកម្ម ក្រសួងកសិកម្ម ក្រសួងសង្គមកិច្ច និងក្រសួងធនធានទឹក។

## ៧. ការរៀបចំទិន្នន័យដើមគ្រា

- ✓ លេខាធិការដ្ឋានបាន និងកំពុងសហការជាមួយក្រសួងអប់រំ ក្នុងការរៀបចំទិន្នន័យដើមគ្រាពាក់ព័ន្ធមុខងារក្នុងវិស័យអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុកទាំង១៤ក្នុងខេត្តបាត់ដំបង។

# I. អំពីវឌ្ឍនភាព (ត)

## ៨. ការតាមដាន ត្រួតពិនិត្យ និងគាំទ្រ

- ✓ លេខាធិការដ្ឋាន បានរៀបចំបង្កើតក្រុមការងារអន្តរក្រសួង រួមមានមន្ត្រីជំនាញនៃក្រសួងអប់រំ ក្រសួងសុខាភិបាល ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមុខងារសាធារណៈ ក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋានគ.ជ.អ.ប ដើម្បីចុះតាមដាន ត្រួតពិនិត្យ និងផ្តល់ការគាំទ្រដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌជាប្រចាំ
- ✓ លេខាធិការដ្ឋាន បានបង្កើតក្រុមការងារទំនាក់ទំនងជាមួយអភិបាលក្រុង ស្រុក ខណ្ឌទូទាំងប្រទេស តាមរយៈប្រព័ន្ធបណ្តាញទំនាក់ទំនងសង្គម (Telegram) ដើម្បីទទួល និងផ្តល់ព័ត៌មានអំពីសំណើសំណូមពរ និងបញ្ហាប្រឈមនានាដែលរដ្ឋបាលក្រុង ស្រុក ខណ្ឌបាននឹងកំពុងជួបប្រទះ។

# II. អំពីបញ្ហាប្រឈម

ទោះបី សម្រេចបាននូវកិច្ចការខាងលើ ក៏ប៉ុន្តែក្នុងការអនុវត្តជាក់ស្តែង រដ្ឋបាលទាំងនេះកំពុងជួបប្រទះបញ្ហាប្រឈមមួយចំនួន ដូចជា ការប្រាស្រ័យទាក់ទងការងារជាមួយស្ថាប័នខាងក្រៅ ការប្រើប្រាស់ត្រារបស់អតីតការិយាល័យជំនាញមួយចំនួន ការផ្តល់សេវាមួយចំនួន ទីកន្លែងឧបករណ៍ សម្ភារបំពេញការងារ ដែលបញ្ហាទាំងនេះកំពុងត្រូវបានសម្របសម្រួល និងដោះស្រាយជាបណ្តើរៗ។ ដោយឡែក បញ្ហាដែលប្រឈមខ្លាំងជាងគេ ដែលលេខាធិការដ្ឋានគោរពស្នើសុំគោលការណ៍ដឹកនាំពី គ.ជ.អ.ប នៅក្នុងកិច្ចប្រជុំនេះ រួមមាន បញ្ហាសំខាន់ចំនួន២ ពោលគឺ៖

១. បញ្ហាពាក់ព័ន្ធនឹងការងារ**<u>បុគ្គលិក</u>**

២. បញ្ហាពាក់ព័ន្ធនឹងការ**<u>ផ្ទេរថវិកា</u>**

# II. អំពីបញ្ហាប្រឈម (ត)

១. <u>បញ្ហាប្រឈមពាក់ព័ន្ធនឹងការងារបុគ្គលិក</u>ៈ

- ការខ្វះមន្ត្រីជំនាញនៅតាមការិយាល័យមួយចំនួនដែលបានបង្កើតរួចហើយ។ ក្នុងចំណោមការិយាល័យ និងអង្គភាពចំណុះរដ្ឋបាលក្រុង ស្រុក ខណ្ឌសរុបចំនួន **២.៦១១** រួមមានការិ. និងអង្គភាពចំនួន១៥៥ ឬស្មើនឹង៦%ពុំទាន់បានរៀបចំឱ្យមានបុគ្គលិកបម្រើការងារ
- ភាពអសកម្មនៃមន្ត្រីមួយចំនួនបានផ្ទេរទៅឱ្យពីមន្ទីរជំនាញមួយចំនួន
- តម្រូវការធនធានថវិកាសម្រាប់ការបណ្តុះបណ្តាលបន្ថែម។

☛ យ៉ាងណាមិញ បញ្ហាប្រឈមដែលពាក់ព័ន្ធទៅនឹងការអនុវត្តតាមគោលការណ៍ដែលបានកំណត់ នោះគឺពាក់ព័ន្ធនឹងការអនុវត្តសិទ្ធិអំណាចរបស់ក្រុង ស្រុក ខណ្ឌក្នុងការតែងតាំង និងផ្លាស់ប្តូរបុគ្គលិកក្រោយសមាហរណកម្ម។

# II. អំពីបញ្ហាប្រឈម (ត)

- ដោយហេតុថា លិខិតបទដ្ឋានគតិយុត្តបានអនុញ្ញាតឱ្យរដ្ឋបាលក្រុង ស្រុកមានសិទ្ធិតែងតាំង ផ្លាស់ប្តូរបុគ្គលិករបស់ខ្លួនក្រោយពេលធ្វើសមាហរណកម្មរួចហើយ អាស្រ័យហេតុនេះ ដើម្បីធានាបាននូវការការងារគ្រប់គ្រងបុគ្គលិក**ក្នុងដំណាក់កាលចំពោះមុខនេះ** លេខាធិការដ្ឋានគោរពស្នើសុំគោលការណ៍ដឹកនាំលើបញ្ហានេះ ដូចខាងក្រោម៖
  - ស្នើសុំក្រសួងមុខងារសាធារណៈដោយមានកិច្ចសហការជាមួយក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន គ.ជ.អ.ប រៀបចំនូវសេចក្តីណែនាំលម្អិតមួយអំពីគោលការណ៍ នីតិវិធី បែបបទ និងលក្ខខណ្ឌនៃការតែងតាំង ផ្លាស់ប្តូរបុគ្គលិកនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ
  - ក្នុងពេលកំពុងរង់ចាំការរៀបចំ និងដាក់ចេញនូវសេចក្តីណែនាំខាងលើនេះ ស្នើសុំក្រសួងមហាផ្ទៃជូនដំណឹងទៅរដ្ឋបាលក្រុង ស្រុក ខណ្ឌក្នុងការពន្យារពេលនូវការតែងតាំង ការផ្លាស់ប្តូរមន្ត្រីរបស់ខ្លួនរហូតដល់ពេលមានការណែនាំជាលម្អិតមួយ។

# II. អំពីបញ្ហាប្រឈម (ត)

## ២. បញ្ហាប្រឈមពាក់ព័ន្ធការផ្ទេរថវិកា៖

- ផ្អែកតាមទិន្នន័យដែលប្រមូលពីក្រសួងពាក់ព័ន្ធបានបង្ហាញថា ថវិកាដែលគ្រោង**ផ្ទេរបន្ថែមទៅ**ឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌសម្រាប់ឆ្នាំ២០២០នេះ រួមមាន៖
  - ❑ ថវិកាសរុបចំនួន **៦៦,៨២ លានដុល្លារ** ដែលក្នុងនោះ៖
    - ✓ ថវិកាសម្រាប់អនុវត្តមុខងារវិស័យអប់រំមានចំនួនសរុបប្រមាណ **៤៤,៥៧ លានដុល្លារ** ដែលក្នុងនោះរួមមាន ៖
      - ○ ថវិកាសម្រាប់ក្រុង ស្រុកទាំង១៤ក្នុងខេត្តបាត់ដំបង (ប្រាក់បៀវត្សគ្រូបង្រៀន និងថវិកាដំណើរការសាលារៀន) មានចំនួន **៣២,២៧ លានដុល្លារ** និង
      - ○ ថវិកាសម្រាប់ការិយាល័យអប់រំនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌទូទាំងប្រទេស (បន្ទុកបុគ្គលិក និងចំណាយប្រតិបត្តិការ) មានចំនួន **១២,៣០ លានដុល្លារ**
    - ✓ ថវិកាសម្រាប់ការិ. ជំនាញ១៩វិស័យផ្សេងទៀត មានចំនួន **២២,២៥ លានដុល្លារ** ដែលក្នុងនោះ៖
      - ○ ចំណាយបន្ទុកបុគ្គលិកមានចំនួនប្រមាណ **១៩,៥ លានដុល្លារ**
      - ○ ចំណាយប្រតិបត្តិការរដ្ឋបាលមានចំនួនប្រមាណ **០,៦៥ លានដុល្លារ (៥.២៦៤៨ X ១២៥$)**
      - ○ ចំណាយសម្រាប់អនុវត្តមុខងារមានចំនួនប្រមាណ **២,១ លានដុល្លារ**

# II. អំពីបញ្ហាប្រឈម (ត)

- ផ្អែកតាមទិន្នន័យខាងលើនេះ យើងបានរួមគ្នាដោះស្រាយនូវការផ្ទេរថវិកាសម្រាប់អនុវត្តមុខងារវិស័យអប់រំ ក៏ប៉ុន្តែ ក្រុមការងារបច្ចេកទេសនៅតែមានជួបប្រទះនូវបញ្ហាប្រឈមក្នុងការដោះស្រាយលើការផ្ទេរថវិកាសម្រាប់មុខងារក្នុងវិស័យ១៩ផ្សេងទៀត
- បញ្ហាប្រឈមដែលកំពុងជួបប្រទះ រួមមាន៖
  I. **ការធានាឱ្យក្រុង ស្រុក ខណ្ឌមានថវិកាបន្ថែមសម្រាប់អនុវត្តមុខងារក្នុងវិស័យទាំង១៩ដែលបានផ្ទេរនៅក្នុងរយៈពេល០៦ខែចុងឆ្នាំ២០២០**
  II. **ការធានាឱ្យក្រុង ស្រុក ខណ្ឌមានថវិកាបន្ថែមសម្រាប់អនុវត្តក្នុងវិស័យទាំង១៩ជាប្រព័ន្ធច្បាស់លាស់ចាប់ពីឆ្នាំ២០២១តទៅ**
- ផ្អែកតាមការជជែកពិភាក្សាក្នុងក្រុមការងារបច្ចេកទេស បានបង្ហាញឱ្យឃើញពីលក្ខណៈស្មុគស្មាញនូវការដោះស្រាយបញ្ហាទាំង២នេះដូចខាងក្រោម៖

# II. អំពីបញ្ហាប្រឈម (ត)

I. ការផ្ទេរថវិកាទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌសម្រាប់អនុវត្តក្នុងរយៈពេល០៦ខែចុងឆ្នាំ២០២០៖

- **បញ្ហាប្រឈម៖**
  - ✓ **ទិដ្ឋភាពច្បាប់៖** ច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ២០២០ និងច្បាប់ទូទាត់ថវិកា។
  - ✓ **ស្ថានភាពជាក់ស្តែងនៃការផ្ទេរថវិកា៖** ថវិកាបានគ្រោងក្នុងកម្មវិធីចំណាយរបស់មន្ទីរជំនាញនានា (បែបបទ នីតិវិធី សមិទ្ធផលនៃការអនុវត្តថវិកាកម្មវិធី)។
  - ✓ **ផលប៉ះពាល់ដោយសារកូវីដ-១៩៖** ការតម្រូវឱ្យមានការកាត់បន្ថយចំណាយតាមស្ថាប័នសាធារណៈនានា ដែលធ្វើឱ្យលំបាកក្នុងការកំណត់ខ្ទង់ថវិកាដែលត្រូវកាត់ទៅឱ្យក្រុង ស្រុក ខណ្ឌ
- **សំណើដំណោះស្រាយ៖**

  ផ្អែកតាមការជជែកពិភាក្សាក្នុងក្រុមការងារបច្ចេកទេស សម្រាប់រយៈ០៦ខែចុងឆ្នាំ២០២០គួរផ្តោតទៅលើការដោះស្រាយលើ៖
  - ✓ ការរៀបចំផ្ទេរថវិកាសម្រាប់**<u>ចំណាយប្រតិបត្តិការរដ្ឋបាល</u>** ដោយមិនទាន់គិតអំពីថវិកាសម្រាប់អនុវត្តមុខងារ និងថវិកាសម្រាប់បន្ទុកបុគ្គលិក។
  - ✓ ការប៉ាន់ប្រមាណលើចំណាយប្រតិបត្តិការរដ្ឋបាលសម្រាប់រយៈពេល០៦ខែចុងឆ្នាំរួមមានប្រមាណ **៣២០.០០០ដុល្លារ** ដែលចំនួននេះត្រូវបានគិតគូរផ្អែកលើអត្រា១២៥ដុល្លារ/នាក់/ឆ្នាំ

# II. អំពីបញ្ហាប្រឈម (ត)

✓ ក្នុងការដោះស្រាយនូវថវិកាសម្រាប់ចំណាយប្រតិបត្តិការរដ្ឋបាលខាងលើនេះ ក្រុមការងារបច្ចេកទេសបានសិក្សាអំពីជម្រើសខុសៗគ្នាចំនួន៣ ពោលគឺ៖

១. ការឧបត្ថម្ភធនបន្ថែមទៀតពីថវិការដ្ឋទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ

២. កំណត់ឱ្យមន្ទីរជំនាញនីមួយៗបន្តប្រើប្រាស់ថវិការបស់ខ្លួនសម្រាប់រ៉ាប់រងលើចំណាយប្រតិបត្តិការរដ្ឋបាលរបស់អតីតបុគ្គលិករបស់ខ្លួនដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុកខណ្ឌ

៣. ការកាត់ចេញពីកញ្ចប់ថវិការបស់មន្ទីរពាក់ព័ន្ធនានា ដើម្បីផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដោយសារថវិកាទាំងនេះបានគ្រោងនៅក្នុងកញ្ចប់ថវិការបស់មន្ទីរជំនាញទាំងនោះ

=> ផ្អែកតាមជម្រើសទាំង៣នេះ លេខាធិការដ្ឋានគ.ជ.អ.ប យល់ឃើញថាគួរគប្បីជ្រើសរើសយកជម្រើសទី១ ដែលមានលក្ខណៈសមស្របជាមួយនឹងក្របខណ្ឌពេលវេលា។

# II. អំពីបញ្ហាប្រឈម (ត)

II. **ការធានាឱ្យក្រុង ស្រុក ខណ្ឌមានថវិកាបន្ថែមសម្រាប់អនុវត្តក្នុងវិស័យទាំង១៩ចាប់ពីឆ្នាំ២០២១តទៅ**

- **បញ្ហាប្រឈម៖**
  - ✓ **ទិដ្ឋភាពលិខិតបទដ្ឋានគតិយុត្ត៖** ជាអនុក្រឹត្យ ឬជាប្រកាសប្រចាំឆ្នាំ ?
  - ✓ **ក្របខណ្ឌពេលវេលា៖** ប្រតិទិននៃការរៀបចំគម្រោងថវិកាឆ្នាំ២០២១
- **សំណើដំណោះស្រាយ៖**
  - ✓ រៀបចំលិខិតបទដ្ឋាន (**ក្នុងកម្រិតប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**) ដើម្បីកំណត់ពីធនធានបន្ថែមពីថវិការដ្ឋ និងនីតិវិធីនៃរៀបចំ និងអនុវត្តថវិការបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌសម្រាប់តែឆ្នាំ២០២១សិន ដើម្បីឱ្យក្រុង ស្រុក ខណ្ឌអាចមានរៀបចំគម្រោងថវិកាឆ្នាំ២០២១បានទាន់ពេលតាមប្រតិទិនកំណត់
  - ✓ ស្នើក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគ្រោងបម្រុងថវិកាមួយចំនួនសមស្របសម្រាប់ផ្ទេរបន្ថែមទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌដោយរួមបញ្ចូលទាំងបន្ទុកបុគ្គលិក ចំណាយប្រតិបត្តិការរដ្ឋបាល និងសម្រាប់អនុវត្តមុខងារក្នុងវិស័យទាំង២០ សម្រាប់ឆ្នាំ២០២១
  - ✓ សម្រាប់ពីឆ្នាំ២០២២តទៅ ការផ្ទេរធនធានថវិកាបន្ថែមត្រូវរៀបចំទៅតាមបែបបទ នីតិវិធីដែលនឹងត្រូវកំណត់ដោយ **អនុក្រឹត្យ**



ការបង្កើតរដ្ឋបាលដែលមានសិទ្ធិធ្វើសេចក្តីសម្រេចចិត្តឱ្យស្ថិតនៅកៀកជិតនឹងប្រជាពលរដ្ឋ
គជអប NCDD
www.ncdd.gov.kh
db.ncdd.gov.kh
www.facebook.com/ncdds/

# III. អំពីផែនការបន្ទាប់

- បន្តការរៀបចំលិខិតបទដ្ឋានផ្ទេរធនធានថវិកាបន្ថែមទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌចាប់ពីដើមឆមាសទី២ ឆ្នាំ២០២០នេះតទៅ និងដើម្បីធានាឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌអាចគ្រោងថវិកាប្រចាំឆ្នាំ២០២១សម្រាប់ដំណើរការពេញលេញតាមមុខងារ និងរចនាសម្ព័ន្ធថ្មីរបស់ខ្លួនស្របតាមប្រតិទិននៃដំណើរការរៀបចំគម្រោងថវិកាប្រចាំឆ្នាំ
- បន្តរៀបចំការផ្ទេរទ្រព្យសម្បត្តិរដ្ឋពាក់ព័ន្ធនឹងវិស័យទាំង២០ទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ
- ការពិនិត្យ និងកែសម្រួលសៀវភៅណែនាំស្តីពីកិច្ចការរដ្ឋបាលរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌឱ្យមានលក្ខណៈសមស្រប និងឆ្លើយតបទៅនឹងមុខងារ និងរចនាសម្ព័ន្ធគ្រប់គ្រងថ្មីរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ
- បន្តរៀបចំវគ្គបណ្តុះបណ្តាលតម្រង់ទិស និងវគ្គបណ្តុះបណ្តាលស្តីពីជំនាញបច្ចេកទេសដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌ
- ក្រុមការងារអន្តរក្រសួង ចុះពិនិត្យស្ថានភាពជាក់ស្តែងនៅតាមក្រុង ស្រុក ខណ្ឌ ដើម្បីស្វែងយល់អំពីបញ្ហាប្រឈមជាក់ស្តែង និងជួយដោះស្រាយបញ្ហាទាំងនោះនៅនឹងកន្លែងផ្ទាល់តែម្តង

# III. អំពីផែនការបន្ទាប់ (ត)

- រៀបចំបញ្ចប់សេចក្តីណែនាំស្តីពីការពិពណ៌នាមុខតំណែងវិជ្ជាជីវៈសម្រាប់ការិយាល័យ និងអង្គភាពនីមួយៗ នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីធានាដល់ការរៀបចំពង្រាយបុគ្គលិកតាមការិយាល័យ និងអង្គភាពនីមួយៗមានលក្ខណៈសមស្រប និងឆ្លើយតបទៅនឹងតួនាទី ភារកិច្ច និងមុខងាររបស់ការិយាល័យ និងអង្គភាពនីមួយៗទាំងនោះ
- រៀបចំការសិក្សាដើម្បីចងក្រងទិន្នន័យដើមគ្រាសម្រាប់វិស័យជាក់លាក់មួយចំនួន ដូចជាវិស័យអប់រំ សុខាភិបាល និងសង្គមកិច្ចជាដើម ដើម្បីធ្វើជាមូលដ្ឋានសម្រាប់ការវាយតម្លៃលើបរិមាណ និងគុណភាពនៃការផ្តល់សេវាក្នុងវិស័យទាំងនោះរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌនាពេលខាងមុខ
- សិក្សា និងរៀបចំយន្តការជាក់លាក់ទាំងនៅថ្នាក់ជាតិ និងថ្នាក់រាជធានី ខេត្តដើម្បីជួយគាំទ្រ តាមដានត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តការងាររបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌតាមមុខងារ និងរចនាសម្ព័ន្ធថ្មីដែលបានកំណត់ដោយអនុក្រឹត្យ និងលិខិតបទដ្ឋានជាធរមាន។

# សូមអរគុណ !